គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

បំរើ ការពារ កសាង

កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ

ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍ ថ្ងៃសុក្រ ទី១២ ខែមិថុនា ឆ្នាំ២០០៩ ព្រឹត្តិប័ត្រលេខ២៨៨ ឆ្នាំទី២


| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -អាជ្ញាធរមូលដ្ឋានធ្វើការរើសអើងប្រជាពលរដ្ឋនៅភូមិសៀមរៀប | ១ |
| -ប្រជាពលរដ្ឋនៅសហគមន៍៧៨មានការព្រួយបារម្ភពីបញ្ហាគ្មានលំនៅឋាន | ២ |
| -បញ្ហាជំលោះដីធ្លីនៅឆ្នាំ២០០៩មានការកើនឡើង | ៣ |
| -អាជ្ញាធររាជធានីភ្នំពេញមិនអនុញ្ញាតឱ្យមជ្ឈមណ្ឌលសិទ្ធិមនុស្សរៀបចំវេទិកាបញ្ចេញមតិ | ៣ |


## អាជ្ញាធរមូលដ្ឋានធ្វើការរើសអើងប្រជាពលរដ្ឋនៅភូមិសៀមរៀប

សកម្មជនគណបក្សសិទ្ធិមនុស្ស នៅឃុំច្រនាង ស្រុកបារាយណ៍ ខេត្តកំពង់ធំបានប្រាប់ថា អាជ្ញាធរភូមិសៀមរៀង និងឃុំច្រនាង រើសអើងប្រជាពលរដ្ឋយ៉ាងសម្បើម ព្រមទាំងគំរាមកំហែង សកម្មជនគណបក្សសិទ្ធិមនុស្ស ចាប់តាំងពីឃុំនេះចាញ់សំលេង ឆ្នោតគណបក្សសិទ្ធិមនុស្ស ក្រោយពីការបោះឆ្នោតថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ កន្លងទៅនេះ ។

តំណាងសកម្មជនគណបក្សសិទ្ធិមនុស្ស ឃុំច្រនាងបាន បន្តទៀតថា អាជ្ញាធរបានកោះហៅសកម្មជនគណបក្សសិទ្ធិមនុស្ស ទៅសាកសួរស្ងាត់ៗ ដើម្បីឱ្យរូបគាត់លាឈប់ពីគណបក្សសិទ្ធិមនុស្ស ប្រសិនបើមិនលាឈប់ទេនោះ ក្រែងលោមានការពាក់ព័ន្ធប៉ះពាល់ ដល់ថ្ងៃក្រោយទៀត ។ សកម្មជនគណបក្សសិទ្ធិមនុស្សនៅ ស្រុកបារាយណ៍បានបញ្ជាក់ថា នៅស្រុកបារាយណ៍មាន១៨ឃុំ ជាទូទៅអាជ្ញាធរតែងតែមាន ការគំរាមកំហែងប្រជាពលរដ្ឋ ។ តួយ៉ាងប្រជាពលរដ្ឋ ចូលរួមស្តាប់កិច្ចសំណេះសំណាលដែលរៀប ចំឡើងដោយគណបក្សសិទ្ធិមនុស្ស ត្រូវបានអាជ្ញាធរកត់ឈ្មោះ ជូនកាលគំរាមកំហែងដល់ផ្ទះសំបែងក៏មាន ។ លោកថាគណបក្ស កាន់អំណាចធ្វើយ៉ាងនេះគឺជាទង្វើរំលោភសិទ្ធិមនុស្ស ។

គួរកត់សំគាល់ថា អាជ្ញាធរមូលដ្ឋានដែលមាននិន្នាការ រឹតត្បឹង និងគណបក្សប្រជាជនកម្ពុជាច្រើនតែបង្ហាញចរិតក្រអឺត ក្រទមលាបពណ៌ប្រជាពលរដ្ឋ និងរើសអើងបក្សពួក ។ សកម្មជន រូបនោះបានបន្តថា អាជ្ញាធរគាបសង្កត់ប្រជាពលរដ្ឋដើម្បីពួក គាត់ដើរតាមរបត់នយោបាយកុម្មុយនិស្ត ។

លោក **សុខ ហួន** មេឃុំច្រនាងបានបដិសេធថា លោក មិនមានការរើសអើងប្រជាពលរដ្ឋ ដូចការចោទប្រកាន់នោះទេ ប្រសិនបើលោកថា លោករើសអើងប្រជាពលរដ្ឋមែននោះលោក នឹងមិនកែប្រែទេ ។

សកម្មជនគណបក្សសិទ្ធិមនុស្សភូមិសៀមរៀង បានរៀប រាប់ថា កាលពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្ររួចមកគណបក្ស សិទ្ធិមនុស្សបានឈ្នះដាច់គេ ដែលទទួលបានលេខ១ គណបក្ស

សមរង្ស៊ីលេខ២ គណបក្សប្រជាជនលេខ៣ ចាប់ពីពេលនោះមក ជារៀងរាល់យប់ថ្ងៃ អាជ្ញាធរភូមិតែងតែដើរមកផ្ទះរបស់គាត់ ។ ស្រាប់តែនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ មានលិខិតមួយច្បាប់បាន កោះហៅរូបគាត់ឱ្យទៅសាលាឃុំច្រនាង ដោយអាជ្ញាធរបាន ចោទប្រកាន់គាត់ថា កាប់រានដីស្រែនៅជើងភ្នំ ។

បើតាមការបញ្ជាក់ប្រាប់ពីសកម្មជនគណបក្សសិទ្ធិមនុស្ស នៅភូមិសៀមរៀងឱ្យដឹងថា លោកមេឃុំ **សុខ ហួន** កោះហៅ រូបគាត់នោះ ដើម្បីល្បួងអូសទាញគាត់ឱ្យចូលជាមួយគណបក្ស ប្រជាជន និងធ្វើជាសមាជិកក្រុមប្រឹក្សាឃុំលំដាប់លេខរៀងទី៤ ។

## ប្រជាពលរដ្ឋនៅសហគមន៍៧៨មាន ការព្រួយបារម្ភពីបញ្ហាគ្មានលំនៅឋាន

នាពេលអនាគតដ៏ខ្លីខាងមុខនេះ គេប្រមើរមើលឃើញ ថាប្រជាសហគមន៍៧៨ ស្ថិតក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន នឹងជួបគ្រោះអភ័ព្វមិនខុសណា និងប្រជាសហគមន៍ដីក្រហម សហគមន៍សំបុកចាប និងសហគមន៍ប្រជា៣ សាសន៍ស្ថិតនៅសង្កាត់ ជ្រោយចង្វាប៉ុន្មានឡើយ ។ បន្ទាប់ពីសហគមន៍ទាំងប៉ុន្មាននោះ ត្រូវបានអាជ្ញាធររាជធានីភ្នំពេញជម្លៀស ពីកណ្តាលក្រុងឱ្យទៅ រស់នៅឆ្ងាយក្រុងប្រឈមនឹងជីវភាពរស់នៅលំបាកវេទនា ។

លោក **ផេង សុវ័ត្ថ** តំណាងប្រជាពលរដ្ឋនៅសហគមន៍ ៧៨បានរៀបរាប់ថា ទោះបីជាសាលារាជធានីភ្នំពេញយកដី សហគមន៍៧៨ទៅអភិវឌ្ឍន៍ ឬយកទៅលក់ឱ្យក្រុមហ៊ុនក៏ដោយ ក្នុងនាមលោកជាប្រជាពលរដ្ឋ ស្នើសុំឱ្យមានសំណងសមរម្យទៅ តាមតំលៃទីផ្សារ ព្រោះប្រជាពលរដ្ឋក៏ដូចជារូបលោកបានរស់នៅ តំបន់៧៨តាំងពីឆ្នាំ១៩៩១-១៩៩៣ ។

លោកបានបន្តថា អាជ្ញាធររាជធានីមានគំរោងឱ្យប្រជា ពលរដ្ឋទៅរស់នៅត្រពាំងអញ្ចាញស្ថិតក្នុងខណ្ឌដង្កោ ដែលដីឡូត៍ នោះទំហំ៤ម ឬបណ្តោយ១២ និងមានទឹកប្រាក់៥០០០ ដុល្លារ ។ ទំហំដី និងទឹកប្រាក់តិចតួចប៉ុណ្ណឹងតើប្រជាពលរដ្ឋរស់នៅយ៉ាង ម៉េចកើត ? អ្វីដែលលោកធ្វើការតវ៉ាទាមទារ មិនមែនជំទាស់ ទៅនឹងការអភិវឌ្ឍន៍ជាមួយអាជ្ញាធរនោះទេ ។ ផ្ទុយទៅវិញ គ្រាន់តែទាមទារនូវសំណង ឱ្យបានសមរម្យក្នុងការរស់នៅតែ ប៉ុណ្ណោះ ។

លោក **អ៊ុំ សំអាត** ប្រធានផ្នែកស៊ើបអង្កេតនៃអង្គការ លីកាដូបានកត់សំគាល់ឃើញថាសាលារាជធានីភ្នំពេញ ក៏ដូចជា សាលាខណ្ឌចំការមន បានចេញសេចក្តីជូនដំណឹងជាញឹកញាប់ឱ្យ ប្រជាពលរដ្ឋដើម្បីផ្លាស់ប្តូរទីលំនៅ ។ សាលារាជធានីបានជូន ដំណឹងជាចុងក្រោយឱ្យប្រជាពលរដ្ឋធ្វើការផ្លាស់ប្តូរ និងទទួល យកគោលនយោបាយរបស់សាលារាជធានីដែលមាន ៣លក្ខខណ្ឌ ទី១. ទទួលយកដី១ឡូត៍ ទំហំ៤ម x ១២ម លុយ ៥០០០ ដុល្លារ ទី២, លុយ១៥០០ និង ផ្ទះមួយទំហំប្រហែល ៤ម x ៦ម នៅ ត្រពាំងអញ្ចាញ និងទី៣,យកលុយ ៨០០០ដុល្លារ ។ការស្រេច ។ ដូច្នេះហើយប្រជាពលរដ្ឋបានកើតទុក្ខមិនសុខចិត្ត និងសេចក្តីជូន ដំណឹងរបស់សាលាស្រុក ។ លោក **អ៊ុំ សំអាត** បានសំដែងការ ព្រួយបារម្ភចំពោះប្រជាសហគមន៍៧៨ ព្រោះកន្លងមកប្រជាសមា គមន៍សំបុក និងដីក្រហមត្រូវបានបណ្តេញចេញពីលំនៅឋាន ។ ជាពិសេសនៅតំបន់ដីក្រហម មានលិខិតជូនដំណឹងជាចុងក្រោយ ឱ្យរុះរើ ហើយនៅពេលពួកគាត់មិនរុះរើលំនៅដ្ឋានត្រូវបានអាជ្ញាធរ ឈូសឆាយកំទេចផ្ទះរបស់ពួកគាត់ចោល ។

យើងមិនអាចសុំការបំភ្លឺពីលោក **ម៉ាន់ ឈឿន** អភិបាល រងរាជធានីភ្នំពេញបានទេ ទាក់ទងនឹងសេចក្តីជូនដំណឹងរបស់ សាលារាជធានីភ្នំពេញ ឱ្យប្រជាសហគមន៍៧៨រុះរើលំនៅដ្ឋានទៅ រស់នៅត្រពាំងអញ្ចាញកាលពីរសៀលថ្ងៃទី០៦ ខែមិថុនានេះ ដោយសារទូរស័ព្ទចូលជាច្រើនលើកប៉ុន្តែមិនមានអ្នកទទួល ។

ជាមួយគ្នានេះលោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការ វិន័យរបស់គណបក្សសិទ្ធិមនុស្សមានប្រសាសន៍ថា គណបក្សកាន់

អំណាចតែងតែបណ្តោយឱ្យអាជ្ញាធរធ្វើការស្រេចតែនឹងចិត្តរបស់ពួកគេ ជាពិសេសធ្វើការគាបសង្កត់លើប្រជាពលរដ្ឋ ។

## បញ្ហាជំលោះដីធ្លីនៅឆ្នាំ២០០៩ មានការកើនឡើង

សង្គមស៊ីវិលបានផ្តល់តំរុយថា រយៈពេល៤-៥ខែក្នុងឆ្នាំ ២០០៩ នេះករណីចាប់ខ្លួនតំណាងអ្នកភូមិដែលតវ៉ា រឿងដីធ្លីមានការកើនឡើង បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០៨កន្លងទៅ ។

អ្នកស្រី **ងួន សូលីដា** អ្នកសំរបសំរួលសមាគមន៍អាដហុក នៅខេត្តស្វាយរៀង បានឱ្យដឹងថាក្នុងឆ្នាំ២០០៩ ទាក់ទងនឹងរឿងទំនាស់ដីធ្លីមានលក្ខណៈធ្ងន់ធ្ងរ ដោយសារមានការចាប់ខ្លួនតំណាងប្រជាពលរដ្ឋនៅស្រុកចន្ទ្រា៣នាក់ និងស្រុកស្វាយទាប២នាក់ ។ ទង្វើរបែបនេះជាការរំលោភសិទ្ធិមនុស្ស ប៉ុន្តែអាជ្ញាធរបែរជាចោទប្រកាន់ និងលើកហេតុផលជារឿងព្រហ្មទណ្ឌទៅវិញ ។

លោក **អ៊ុំ សំអាត** ប្រធានផ្នែកស៊ើបអង្កេតអង្គការលីកាដូបានកត់សំគាល់ឃើញថា អាជ្ញាធរបានចាប់ខ្លួនប្រជាពលរដ្ឋដែលធ្វើការតវ៉ាដូចជានៅខេត្តសៀមរាប ខេត្តរតនៈគីរី និងថ្មីៗនេះយើងមានការព្រួយបារម្ភទាក់ទងនឹងការចាប់ខ្លួនប្រជាពលរដ្ឋនៅភូមិឡពាង ឃុំតាជេស្ត ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលតុលាការកំពុងតែកោះហៅរូបគាត់ ។ សង្គមស៊ីវិលមានការព្រួយបារម្ភខ្លាចក្រែងមានការចាប់ខ្លួនថាបន្តបន្ទាប់ទៀត ។

លោក **អ៊ុំ សំអាត** បានបន្តថា ការចាប់ខ្លួននេះបើធៀបនឹងឆ្នាំ២០០៨ ឃើញថាមានការកើនឡើង ដោយសារចំនួនមនុស្សដែលត្រូវចាប់មានការកើនជាងឆ្នាំ២០០៨ ។ នៅឆ្នាំ២០០៩ ករណីចាប់ខ្លួនក៏មានការស្លាប់ និងបង្ករបួសស្នាមក៏មាននេះដោយសារការបាញ់ ទៅលើតំណាងប្រជាពលរដ្ឋដោយកងកំលាំងប្រដាប់អាវុធ ។

អង្គការលីកាដូមានការព្រួយបារម្ភ ចំពោះការចាប់ខ្លួនតំណាងប្រជាពលរដ្ឋ ពីព្រោះតំណាងប្រជាពលរដ្ឋធ្វើការតវ៉ាដើម្បីផលប្រយោជន៏របស់ប្រជាពលរដ្ឋទូទៅដែលបានបាត់បង់ដីធ្លី ។

លោក **ចាន់ សូវ៉ែត** មន្រ្តីស៊ើបអង្កេតជាន់ខ្ពស់នៃសមាគមន៏អាដហុកបានបន្ថែមដែរថា ចាប់ពីដើមឆ្នាំ ២០០៩ មកដល់ពេលនេះតាមតួលេខបណ្តោះអាសន្ន ស្តែងឱ្យឃើញថាមិនតិចជាងករណី ដែលប្រជាពលរដ្ឋទទួលរងគ្រោះដោយការចោទប្រកាន់តាមផ្លូវតុលាការក្នុងរឿងទំនាស់ដីធ្លី ។ ជាមួយគ្នានេះក៏មានប្រជាពលរដ្ឋប្រមាណជាង៥០នាក់ ហើយដែលកំពុងជាប់ពន្ធនាគារខេត្តក្រុង ។ លោក **ចាន់ សូវ៉ែត** បានសង្កត់ធ្ងន់ថាការចាប់ខ្លួនតំណាងប្រជាពលរដ្ឋ ក្រោមហេតុផលភ្នាក់ងារអាជ្ញាធរមូលដ្ឋានសហការជាមួយក្រុមហ៊ុនប្តឹងប្រជាពលរដ្ឋពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិពីបទប្លន់ និងពីបទបង្ករបួសស្នាម ។ ជុំវិញរឿងទំនាស់ដីធ្លីគេប្រែក្លាយរឿងស៊ីវិលឱ្យក្លាយទៅជារឿងព្រហ្មទណ្ឌ ។ ពាក់ព័ន្ធនឹងរឿងទំនាស់ដីធ្លីគួរតែអាជ្ញាធរមូលដ្ឋានជាមួយក្រុមហ៊ុនគួរអនុវត្តច្បាប់ឱ្យត្រឹមត្រូវ ។

## អាជ្ញាធររាជធានីភ្នំពេញមិនអនុញ្ញាតឱ្យមជ្ឈមណ្ឌលសិទ្ធិមនុស្សរៀបចំវេទិកាបញ្ចេញមតិ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានសំដែងការមិនពេញចិត្តចំពោះអាជ្ញាធរខណ្ឌដូនពេញ និងរាជធានីភ្នំពេញដែលបានបន្ទុចបង្អាក់រារាំងដំណើរការ រៀបចំវេទិកាបញ្ចេញមតិដែលគ្រោងនឹងរៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០៩ នៅផ្ទះសំណាក់ Zazy Fish ស្ថិតក្នុងសង្កាត់ស្រះចកខណ្ឌដូនពេញ ។

លោក **សារ៉ាវុធ តំណាង** មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានថា មជ្ឈមណ្ឌលបានជួលផ្ទះសំណាក់ Zazy Fishដើម្បី

រៀបចំវេទិកាបញ្ចេញមតិនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៩ ហើយក៏បាននិយាយត្រូវរ៉ូវជាមួយម្ចាស់ផ្ទះសំណាក់ ដោយកក់លុយគាត់រួចហើយដែរ ។ ប៉ុន្តែអាជ្ញាធរមូលដ្ឋានបានហាមឃាត់ម្ចាស់ផ្ទះសំណាក់មិនឱ្យជួលទីតាំងបញ្ចេញមតិដល់ មជ្ឈមណ្ឌលនោះទេ ហើយប្រសិនបើនៅតែជួល អាជ្ញាធរនឹងបិទអាជីវកម្មផ្ទះសំណាក់នោះជាមិនខាន ។ លោកបានគូសបញ្ជាក់ទៀតថា រហូតមកដល់ពេលនេះកងកំលាំងខណ្ឌដូនពេញ បិទផ្ទះសំណាក់បាត់ទៅហើយក្រោមលេសថាហួសអាជ្ញាប័ណ្ណ ។ សកម្មភាពនេះជាការបំបិទសេរីភាពបញ្ចេញមតិ និងផ្ទុយអំពីច្បាប់រដ្ឋធម្មនុញ្ញ ។

តំណាងម្ចាស់ផ្ទះសំណាក់យីហោ Zazy Fish បានឆ្លើយតបនឹងសំណួររបស់យើងថា ផ្ទះសំណាក់របស់លោកអស់អាជ្ញាប័ណ្ណ ហើយអាជ្ញាធរឱ្យបិទជាបណ្តោះអាសន្ន ។ ហើយប្រការដែលអាជ្ញាធរបិទផ្ទះសំណាក់ របស់លោកមិនមែនមកពីលោកជួលទីតាំងឱ្យមជ្ឈមណ្ឌលរៀបចំសិទ្ធិបញ្ចេញមតិនោះទេ ព្រោះលោកបានលុបចោល ក្នុងការជួលទីកន្លែងនោះហើយតែតាមការពិតគឺលោកហួសអាជ្ញាប័ណ្ណ ។

លោក **ច័ន្ទ សុវៃត** មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់នៃសមាគមអាដហុកបានចង្អុលបង្ហាញថា យើងដូចជាមានមន្ទិលសង្ស័យចំពោះផ្ទះសំណាក់នោះ ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សបានជួលដើម្បីរៀបចំវេទិកាសាធារណៈ ក្នុងការដោះស្រាយវិវាទដីធ្លីនៅបឹងកក់តែបែរជាមិនបាន ប្រហែលជាម្ចាស់ផ្ទះសំណាក់រងការគាបសង្កត់ពីអាជ្ញាធរមិនឱ្យជួលទីតាំងសំរាប់មជ្ឈមណ្ឌល ។

លោក **ច័ន្ទ សុវៃត** បានបន្ថែមថា សេរីភាពមួយចំនួនទទួលរងការចោទប្រកាន់ ឬប្តឹងប្តល់ ហើយថ្មីៗនេះមន្ត្រីគណបក្សនយោបាយត្រូវធ្វើការប្តឹងប្តល់ ដោយសារការផ្សាយពតិមានមិនពិតទៅលើអ្នកសារពតិមាន និងអង្គការសង្គមស៊ីវិលរងការគាបសង្កត់ក្នុងការសាកសួរពតិមាន ។ ទិដ្ឋភាពនេះបង្ហាញថាសេរីភាពសារពតិមាននៅប្រទេសកម្ពុជា យើងសព្វថ្ងៃនេះ ហាក់ដូចមានការថមថយពីព្រោះប្រជាពលរដ្ឋមានការភ័យខ្លាច ។

យើងមិនអាចទាក់ទង ដើម្បីសុំការស្រាយបញ្ជាក់ពីលោក **សុខ សម្បត្តិ** អភិបាលខណ្ឌដូនពេញបាន ទេជុំវិញការបិទផ្ទះសំណាក់យីហោ Zazy Fish ដោយសារការប្រាស្រ័យទាក់ទងតាមទូរស័ព្ទអាក់រអួល បន្ទាប់មកលោកមិនលើកទូរស័ព្ទ ។

សូមជំរាបថា មជ្ឈមណ្ឌលសិទ្ធិមនុស្សបានព្យាយាមរៀបចំវេទិកាបញ្ចេញមតិនៅក្រុងភ្នំពេញ ពីរលើករួមទាំងលើកនេះផងដែរ ប៉ុន្តែអាជ្ញាធររាជធានីភ្នំពេញ តែងតែបង្ករាំងស្ទះដល់ដំណើរការរៀបចំវេទិកាបញ្ចេញមតិរបស់មជ្ឈមណ្ឌល ។ ពាក់ព័ន្ធនឹងន័យដែររបាយការណ៍សិទ្ធិមនុស្សឆ្នាំ២០០៨ របស់ក្រសួងការបទេសសហរដ្ឋអាមេរិកបានសង្កេតសំគាល់ឃើញថា រដ្ឋាភិបាលបានដាក់កំរិតសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពពតិមានហើយក៏បានជ្រៀតជ្រែកនៅក្នុងសេរីភាពនៃការជួបជុំគ្នា ។


| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| លោក | ម៉ី សាន | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| កញ្ញា | គង់ ចណ្ណា | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |


**សេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា ត្រូវប្រឈមនឹងបទល្មើសបរិហារកេរ្តិ៍ !**